**សលាកប័ត្រព័ត៌មាន** ៖ បុរីកីឡា~ទំនាស់ដីពុំរ៉ៃនៅតែបន្ត

**កាលប្បវត្តិ** ៖ ពីខែមករា ឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន

**ទិដ្ឋភាពរួម** ៖ បន្ទាប់ពីរង់ចាំដំណោះស្រាយអស់រយៈពេលជិតបួនឆ្នាំចាប់តាំងពីមានការបណ្ដេញចេញដោយហិង្សា អតីតប្រជាពលរដ្ឋបុរីកីឡាបានខកចិត្តជាខ្លាំងទៅនឹងសេចក្ដីសម្រេចប្រកាសឡើងនាពេលថ្មីៗនេះរបស់សាលារាជធានីភ្នំពេញដែលបានបង្ហាញថាភាគច្រើននៃគ្រួសារដែលសេសសល់ត្រូវបានបដិសេធក្នុងការទទួលបានលំនៅដ្ឋាននៅនឹងកន្លែង តាមការសន្យាពីដំបូងរបស់ក្រុមហ៊ុនផានអ៊ីមិច ។

## សេចក្ដីផ្ដើម

ការរំលោភសិទ្ធិដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា("កម្ពុជា") គឺជារូបភាពធម្មតាទៅហើយ ដោយសារតែមហិច្ឆតារបស់អ្នកមានទ្រព្យស្ដុកស្ដម្ភ និងជនមានអំណាចមួយចំនួននៅកម្ពុជាបានចាប់ឱកាសវិនិយោគដោយរំលោភទៅលើសិទ្ធិមូលដ្ឋានគ្រឹះរបស់ប្រជាពលរដ្ឋសាមញ្ញដូចជាករណីនៅបុរីកីឡាជាឧទាហរណ៍ស្រាប់។ សលាកប័ត្រព័ត៌មាននេះនឹងលើកឡើងនូវករណីបុរីកីឡាជាឧទាហរណ៍នៃកិច្ចសហប្រតិបត្តិការដោយជោគជ័យលើបញ្ហាដីធ្លីរវាងសហគមន៍មួយនិងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ដែលករណីនេះមានជាប់ពាក់ព័ន្ធក្នុងការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។

សលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្ខសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា ។

## តើករណី នេះកើតឡើងចាប់តាំងពីពេលណា ?

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកើនឡើងជិតដប់ភាគរយក្នុងមួយៗឆ្នាំនៅចន្លោះឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨ ដែលនាំឱ្យវិនិយោគិនបរទេស ជាពិសេសអ្នកវិនិយោគមកពីបណ្ដាប្រទេសក្នុងតំបន់អាស៊ីដូចជា ចិន ថៃ និងវៀតណាមបានសម្លឹងមើលឱកាសនៃការធ្វើអាជីវកម្ម។ ដោយសារសេដ្ឋកិច្ចក្នុងប្រទេសទទួលបានជោគជ័យ សំណង់អគារប្រណិតៗខ្ពស់ត្រដែតចាប់ផ្ដើមបង្ហាញខ្លួននៅទូទាំងរាជធានីភ្នំពេញ។ ជាទីក្រុងមួយដំដីនៅក្នុងរាជធានីភ្នំពេញគឺមានតំលៃខ្ពស់ ដែលបានទាក់ទាញវិនិយោគិនផ្នែកអចលនៈទ្រព្យចាប់ឱកាសរកប្រាក់ចំណេញទៅលើអាជីវកម្មនោះ ។

បុរីកីឡាជាតំបន់មួយនៅចំកណ្ដាលរាជធានីភ្នំពេញ ដែលមានផ្ទៃដី ១៤,១២ ហិកតា និងធ្លាប់ជាលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន ១.៧៧៦ គ្រួសារ។ ក្នុងឆ្នាំ២០០៣ រដ្ឋាភិបាលបានធ្វើសម្បទានដល់ក្រុមហ៊ុនឯកជនមួយឈ្មោះក្រុមហ៊ុនផានអ៊ីមិច ("ផានអ៊ីមិច") កម្មសិទ្ធិរបស់អ្នកស្រី ស៊ុយ សុផាន អ្នកជំនួញជនជាតិខ្មែរដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរដ្ឋាភិបាលទទួលបានសិទ្ធិអភិវឌ្ឍនៅបុរីកីឡាក្រោម "កិច្ចព្រមព្រៀង

ចែករំលែកដី" ។ លោកនាយករដ្ឋមន្រ្តី ហ៊ុន សែន បានផ្តល់សម្បទានដីសង្គមកិច្ចលើផ្ទៃដីទំហំប្រមាណ ៤,៦ ហិចតាដល់សហគមន៍បុរីកីឡា និងដោយមានកិច្ចព្រមព្រៀងចែករំលែកដីនោះជាមួយក្រុមហ៊ុនផានអ៊ីម៉ិច ដែលជាប់កាតព្វកិច្ចសាងសង់អគារចំនួនដប់លើផ្ទៃដីទំហំពីរហិចតាដើម្បីសង់លំនៅដ្ឋានជូនប្រជាពលរដ្ឋនៅបុរីកីឡាជាថ្នូរនឹងការទទួលបានសិទ្ធិអភិវឌ្ឍលើផ្ទៃដីដែលនៅសល់ទំហំ ២,៦ ហិកតា ។

**តើកំហុសឆ្គងនៅត្រង់ចំណុចណា?**

កំហុសឆ្គងនោះគឺនៅត្រង់ថាក្រុមហ៊ុនផានអ៊ីមិចមិនបានធ្វើតាមការសន្យារបស់ខ្លួនឡើយ។ នៅក្នុងខែមេសា ឆ្នាំ២០១០ បន្ទាប់ពីសាងសង់បានអគារចំនួន៨ ក្នុងចំណោមអគារចំនួន១០ ដែលខ្លួនបានសន្យានោះ ក្រុមហ៊ុនផានអ៊ីមិចបានផ្អាកការសាងសង់ដោយអះអាងថាខ្វះថវិកា ហើយប្រការនោះបានបន្សល់ទុកប្រជាពលរដ្ឋចំនួនប្រមាណ៣០០គ្រួសារគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមហ៊ុនផានអ៊ីមិច អាចទទួលបានដោយជោគជ័យពីរដ្ឋាភិបាលនូវដីបម្រុងទុកសម្រាប់សង់អគារចំនួនពីរដែលនៅសល់នោះទៀតផង ។

នៅថ្ងៃទី០៣ និងថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ ករណីនៅបុរីកីឡាបានធ្វើឱ្យមជ្ឈដ្ឋានទូទៅដឹងឮជាសាធារណៈ នៅពេលដែលក្រុមគ្រួសារនៅសេសសល់ត្រូវបានបណ្តេញចេញដោយហិង្សាពីផ្ទះសម្បែងរបស់ខ្លួនពីសំណាក់កងសន្តិសុខរបស់ក្រុមហ៊ុនផានអ៊ីមិច និងកងកម្លាំងសមត្ថកិច្ចចម្រុះព្រមទាំងកងរាជអាវុធហត្ថដែលបង្ហាញពីការពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលក្នុងករណីនេះ ។ សកម្មភាពបណ្តេញចេញទាំងនោះធ្វើឡើងតាមរយៈការយកគ្រឿងចក្រឈូសឆាយផ្ទះសម្បែង ប្រើដំបងឆក់និងឧស្ម័នបង្ហូរទឹកភ្នែក ។ ក្នុងអំឡុងពេលការបណ្តេញចេញនោះ មានផ្ទះសម្បែងជាង២០០ខ្នងត្រូវបានកម្ទេច ហើយប្រជាពលរដ្ឋជាច្រើននាក់បានរងរបួសនិងមួយចំនួនផ្សេងទៀតត្រូវបានចាប់និងឃុំខ្លួន។

ដោយមិនបានទទួលលំនៅដ្ឋានអចិន្ត្រៃយ៍ដែលជាសំណងនៃការបណ្តេញចេញដោយបង្ខំនោះទេ គ្រួសារភាគច្រើនត្រូវបានបង្ខំឱ្យទៅតាំងទីលំនៅថ្មីនៅតំបន់ដាច់ស្រយាលចំនួនពីកន្លែង ដែលមួយកន្លែងស្ថិតនៅទួលសំបូរ ចម្ងាយ២៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ ក្នុងឃុំព្រៃវែង និងមួយកន្លែងទៀតនៅស្រះពោធិ៍ (ដែលគេស្គាល់ថាភ្នំបាត) ក្នុងខេត្តកណ្តាលចម្ងាយ៤៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ ។ ស្ថានភាពក្នុងតំបន់ទីតាំងថ្មីទាំងនោះមានសភាពលំបាកវេទនាដោយប្រជាពលរដ្ឋរស់នៅក្រោមក្រណាត់តង់ជាបណ្តោះអាសន្ន និងបានប្រឈមនឹងបញ្ហាជាច្រើនដូចជាពុំមានភ្លើងអគ្គិសនី អនាម័យ ទឹកស្អាត សាលារៀននិងឱកាសការងារឡើយ។ សំរាមគរឡើងកាន់តែច្រើនព្រមទាំងបរិស្ថានមិនល្អបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់ប្រជាពលរដ្ឋដែលងាយប្រឈមនឹងការឆ្លងជម្ងឺផ្លូវដង្ហើម និងជម្ងឺរាគជាដើម។

**តើមានករណីអ្វីខ្លះបានកើតឡើងចាប់តាំងពីការបណ្តេញចេញលើកដំបូង?**

ចាប់តាំងពីមានឧប្បត្តិហេតុដ៏អាក្រក់កាលពីខែមករា ឆ្នាំ២០១២ បញ្ហានេះមានការយឺតយ៉ាវក្នុងការរកដំណោះស្រាយ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារដែលត្រូវបានប្តូរទីលំនៅបានបដិសេធទៅរស់នៅលើទីតាំងថ្មី ហើយបានត្រឡប់មករស់នៅបុរីកីឡាវិញក្រោមក្រណាត់តង់ជាបណ្តោះអាសន្ននៅតាមបណ្តោយអគារដែល

បានសាងសង់រួចនោះក្នុងស្ថានភាពយ៉ាងអាក្រក់។ ចាប់តាំងពីពេលនោះមកប្រជាពលរដ្ឋទាំងនោះបានប្រឈមមុខនឹងការបង្ក្រាបដោយហិង្សានិងការបណ្តេញចេញពីលំនៅដ្ឋានជាច្រើនលើក។

នៅខែឧសភា ឆ្នាំ២០១៣ ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញបានសន្យាដោះស្រាយទំនាស់នោះ ប៉ុន្តែដោយសារតែដំណើរការដោះស្រាយនេះមានភាពយឺតយ៉ាវនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ ប្រជាពលរដ្ឋបុរីកីឡាបានតវ៉ាក្នុងរាជធានីភ្នំពេញ ដោយរងការបង្ក្រាបធ្ងន់ធ្ងរពីសំណាក់នគរបាលដែលបណ្តាលឱ្យស្ត្រីជាច្រើននាក់សន្លប់។ ជាការពិត គ្រួសារពលរដ្ឋដែលរងផលប៉ះពាល់បានតវ៉ាជាច្រើនលើកច្រើនសារដើម្បីទាមទារដំណោះស្រាយក្នុងបញ្ហានោះ ដែលជាញឹកញាប់ពួកគាត់បានពើបប្រទះនឹងអំពើហិង្សាពីសំណាក់អាជ្ញាធររបស់រដ្ឋាភិបាល។

ការបង្ហាញសញ្ញានៃការស្វាបស្ទង់មួយជាជំហានឈានដល់ដំណោះស្រាយជាលើកដំបូងនោះ គឺនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ នៅពេលដែលប្រជាពលរដ្ឋបុរីកីឡាប្រមាណ ២០០ នាក់បានជួបប្រជុំជាមួយមន្ត្រីសាលារាជធានីភ្នំពេញក្នុងវេទិកាសាធារណៈមួយ ដែលនៅពេលនោះមន្ត្រីសាលារាជធានីភ្នំពេញបានស្នើឱ្យប្រជាពលរដ្ឋផ្តល់ឯកសារបញ្ជាក់ថាពួកគាត់ "ពិតជាជនរងគ្រោះ" ប្រាកដមែន។ ក្រុមការងារមួយត្រូវបានបង្កើតឡើងដើម្បីពិនិត្យមើលនូវជម្រើសលើទីតាំងថ្មីនិងប្រាក់សំណងសម្រាប់ប្រជាពលរដ្ឋទាំងនេះ។ បន្ទាប់ពីការវាយតម្លៃលើកទីមួយនៅក្នុងខែមីនា ឆ្នាំ២០១៥ ហើយនៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ត្រូវបានប្រកាសថាគ្រួសារចំនួន ១៥៤ ក្នុងចំណោមប្រជាពលរដ្ឋចំនួន ១៨៣ គ្រួសាររស់នៅបុរីកីឡាមានសិទ្ធិទទួលបានសំណង។

បន្ទាប់ពីការរង់ចាំដំណោះស្រាយអស់រយៈពេលជិតបួនឆ្នាំ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សាលារាជធានីភ្នំពេញបានកំណត់ជាចុងក្រោយថា មានតែប្រជាពលរដ្ឋចំនួន ៣៥ គ្រួសារប៉ុណ្ណោះដែលនឹងមានសិទ្ធិទទួលបានលំនៅដ្ឋាននៅបុរីកីឡា។ ប្រជាពលរដ្ឋចំនួន ៨៥ គ្រួសារត្រូវបានជូនដំណឹងថានឹងត្រូវប្តូរទីលំនៅទៅភូមិអណ្តូង ជាយរាជធានីភ្នំពេញ ឬទទួលបានប្រាក់សំណងចំនួន ៥,០០០ ដុល្លាអាមេរិក ទីតាំងភូមិអណ្តូងគឺជាទីតាំងដែល ម.ស.ម.ក ធ្លាប់បានប្រកាសថាកន្លែងមិនសមរម្យ។[1] ប្រជាពលរដ្ឋចំនួន ៣៤ គ្រួសារទៀតដែលពុំមានឯកសារគ្រប់គ្រាន់ដើម្បីបង្ហាញថាជាអតីតអ្នករស់នៅបុរីកីឡា នឹងទទួលបានដំណោះស្រាយជាគោលនយោបាយដោយទទួលបានទឹកប្រាក់ចំនួន ៣.០០០ ដុល្លាអាមេរិក។ ការកំណត់នោះត្រូវបានរិះគន់ជាខ្លាំងពីសំណាក់ប្រជាពលរដ្ឋទាំងនោះហើយពួកគាត់មានរយៈពេលតែ ៣០ ថ្ងៃប៉ុណ្ណោះក្នុងការប្តឹងជំទាស់។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គួរឱ្យសោកស្តាយចំពោះការកំណត់សំណងក្នុងខែវិច្ឆិកានេះ ដែលមិនបង្ហាញនូវសញ្ញាឈានដល់ការបញ្ចប់បញ្ហារបស់ប្រជាពលរដ្ឋជាជនរងគ្រោះនៅបុរីកីឡានោះទេ ដោយហេតុថា ជនរងគ្រោះភាគច្រើនត្រូវបានផ្តល់សំណងតិចតួចក្នុងខណៈដែលពួកគាត់ធ្លាប់បានទទួលរងការរំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់ និងជាច្រើន

---

[1] របាយការណ៍របស់ ម.ស.ម.ក " កម្ពុជា ៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី " (ខែធ្នូ ឆ្នាំ២០១៣) អាចស្វែងរកបានតាមរយៈ http://bit.ly/1KtPNVy។

លើកច្រើនសារដែលបានរងការឈឺចាប់ដោយសារការបង្ក្រាបរបស់កងរក្សាសន្តិសុខរបស់ក្រុមហ៊ុនផានអ៊ីមិច និងរាជរដ្ឋាភិបាល។ ទន្ទឹមនេះដែរ ម.ស.ម.ក សូមស្វាគមន៍ចំពោះកិច្ចប្រឹងប្រែងរបស់អាជ្ញាធររាជធានីភ្នំពេញ ក្នុងការដោះស្រាយករណីនេះ ប៉ុន្តែចំណុចសំខាន់គួរកត់សម្គាល់នោះគឺសង្គមស៊ីវិលបានបង្ហាញនូវភស្តុតាងដល់អាជ្ញាធរក្រុងថាមានគ្រួសារជាច្រើនទៀតមានសិទ្ធិទទួលបានលំនៅដ្ឋាននៅបុរីកីឡា ហើយករណីនេះគួរតែត្រូវធ្វើការវាយតម្លៃឡើងវិញ។ ម្យ៉ាងទៀត ម.ស.ម.ក ស្នើអាជ្ញាធរនិងក្រុមហ៊ុនផានអ៊ីមិចមេត្តាពិចារណាចំពោះការផ្តល់ប្រាក់សំណង និងតំឡើងប្រាក់សំណងឱ្យបានសមស្របទៅតាមតំលៃដីនាពេលបច្ចុប្បន្ន។ ប្រាកដណាស់ក្នុងកាលៈទេសៈបែបនេះ ម.ស.ម.ក នឹងបន្តការងាររបស់ខ្លួនក្នុងនាមជាអ្នកសង្កេតការណ៍ទៅលើកិច្ចពិភាក្សា និងព្រឹត្តិការណ៍នានា។ ជាមួយគ្នានេះ អាជ្ញាធរនានាមិនត្រូវចាត់វិធានការដោយបង្ខំណាមួយទៅលើប្រជាពលរដ្ឋដែលតវ៉ាដើម្បីទទួលបានសំណងសមរម្យជាងនេះនោះទេ ហើយត្រូវគោរពដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិជាមូលដ្ឋានរបស់ពលរដ្ឋផងដែរ។ ជាទីបញ្ចប់ សូមស្នើអាជ្ញាធរមេត្តាបន្តនូវកិច្ចប្រឹងប្រែងក្នុងការស្វែងរកដំណោះស្រាយលើករណីទំនាស់ដ៏រ៉ាំរ៉ៃនេះជូនដល់អតីតប្រជាពលរដ្ឋបុរីកីឡា ព្រមទាំងករណីជម្លោះដីធ្លីដទៃទៀតនៅទូទាំងប្រទេសកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សូផាត មន្ត្រីសម្របសម្រួលកម្មវិធីកំណែទម្រង់ដីធ្លី ម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (០) ១២ ៩៤១ ២០១៦ ឬ អ៊ីម៉ែល ៖** vann.sophath@cchrcambodia.org **ឬកញ្ញា អាលីហ្សា ខាំបៃយ៍ ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ + ៨៥៥ (០) ១២ ៤៧៩ ១៧៩ ឬ អ៊ីម៉ែល ៖** alysha.khambay@cchrcambodia.org។